ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំពិភាក្សា

## ស្តីពី កិច្ចសហការដើម្បីឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍ និងជនងាយរងគ្រោះ

**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបើកកិច្ចប្រជុំពិភាក្សា ស្តីពីកិច្ចសហការដើម្បីឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ពាក់ព័ន្ធពលករទេសន្តរប្រវេសន៍ និងជនងាយរងគ្រោះ នៅថ្ងៃអង្គារ បីកើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ពីរពាន់ប្រាំរយហុកសិបបួន ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោង ៨ប់មួយព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយតំណាង អង្គការសហប្រជាជាតិនៅកម្ពុជា ចំនួន០៥ ក្នុងនោះរួមមាន **លោកស្រី** Pauline Tamesis ប្រធានក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា (Head of UN Team) , **លោកស្រី** Li Ailan តំណាងអង្គការសុខភាពពិភពលោក WHO, **លោកស្រី** Kristin Parco នាយិកាប្រចាំប្រទេស អង្គការ IOM, **លោក** Daniel Alemu ប្រធានអង្គការ UNFPA និងលោក លឹម ទិត្យ មន្ត្រីគម្រោង, លោកស្រី Luda Solen ប្រធានគម្រោងការពារកុមារ អង្គការ UNICEF ។ កិច្ចប្រជុំ មានការចូលរួមពី **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណា សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម សួស ប្រាថ្នា អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ** តំណាងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជំនួយការ ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ តំណាង NCDD ព្រមទាំង ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង និងជាប្រធានក្រុមការងារបច្ចេកទេសទាំង ០៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមន្ត្រីពាក់ព័ន្ធ **សរុប ២០ រូប ស្រី ៨ រូប** ។

ក្នុងមតិផ្តើម **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានស្វាគមន៍ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី និងតំណាងអង្គការសហប្រជាជាតិ ទាំងអស់ ដែលបានចំណាយពេលចូលរួមក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់ ស្តីពីការត្រៀមរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសអង្គការសហប្រជាជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** នាពេលខាងមុខ ។

**លោកស្រី** Lauline Tamesis ប្រធានក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UN) បានស្នើឡើងនូវរបៀបវារៈ នៃកិច្ចប្រជុំពិភាក្សា ០៣ចំណុច គឺៈ

១.គម្រោងថវិកាដែលអង្គការសហប្រជាជាតិ (UN) គ្រោងឡើងដើម្បីគាំទ្ររាជរដ្ឋាភិបាលដោះស្រាយបញ្ហាក្នុងដំណាក់កាលវិបត្តិខូវីដ ១៩

២.គម្រោងផែនការសកម្មភាពរួមគ្នា

៣.ការសម្របសម្រួលកិច្ចសហការ ។

ពាក់ព័ន្ធនឹងរបៀបវារៈទី១ លោកស្រី បានបញ្ជាក់ថា គម្រោងថវិកាអង្គការសហប្រជាជាតិ ឆ្លើយតបវិបត្តិកូវីដ-១៩ ដែលត្រូវយកមកគាំទ្ររាជរដ្ឋាភិបាលកម្ពុជានេះ មានចំនួន មួយលានដុល្លា សម្រាប់គាំទ្រដល់ប្រជាជនកម្ពុជា ក្នុងចំណោមជនទេសន្តរប្រវេសន៍ វិលត្រឡប់ និងសហគមន៍ ក្នុងខេត្តបី គឺខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប និងមានរយៈពេល តែ ០៦ខែប៉ុណ្ណោះ ។ ហេតុនេះ ការអនុវត្តគម្រោង ត្រូវតែដាក់លាក់ និងចាប់ផ្តើមឲ្យបានឆាប់ ដើម្បីទទួលបានលទ្ធផល ។ គម្រោងថវិកានេះ ទទួលបានបន្ទាប់ពីលទ្ធផលនៃកិច្ចប្រជុំ លើកទី១ ជាមួយអន្តរក្រសួង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នាថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០ ដែលមានរយៈពេលសរសេរគម្រោងត្រឹមតែ ៦ថ្ងៃប៉ុណ្ណោះ ត្រូវផុតកំណត់ ។ ថវិកានេះមានចំនួនតិចតួច មិនគ្រប់គ្រាន់សម្រាប់ការគ្របដណ្តប់លើគ្រប់គោលដៅទូទាំងប្រទេសឡើយ ហេតុនេះ យើងនឹងស្នើសុំឲ្យមានការចូលរួមគាំទ្រពីស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល និងដៃគូដទៃទៀតលើគម្រោងនេះ ។ សំណើថវិកាសម្រាប់ការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ គឺផ្អែកតាមផែនការសេដ្ឋកិច្ច-សង្គម របស់អង្គការសហប្រជាជាតិ សម្រាប់ការផ្តល់សេវាគាំទ្រដល់ជនទេសន្តរប្រវេសន៍ដែលងាយរងគ្រោះ សេវាសុខភាពស្ត្រី កុមារ សុខភាពមាតា និងទារក និងប្រជាពលរដ្ឋងាយរងគ្រោះក្នុងសហគមន៍ ជាពិសេសផលប៉ះពាល់ដល់គ្រួសារដែលមានស្ត្រីជាមេផ្ទះ ។

**លោកស្រី Kristin Parco នាយិកា អង្គការ IOM** មានប្រសាសន៍ថា គោលបំណងធំ គឺការការពារពលករកុំឲ្យមានការឆ្លងជំងឺកូវីដ-១៩ និងផ្តល់ការគាំទ្រតាមតម្រូវការចាំបាច់ សមស្រប ។ ការងារនេះនឹងផ្តោតលើគោលការណ៍ដែលបានពិភាក្សាកន្លងមក គឺ (១). សុខភាព និងកិច្ចការពារ (២). ជីវភាព និងអាហារូបត្ថម្ភ ។ កម្មវិធីផ្តោតលើគោលដៅសំខាន់បី គឺ៖ ទី១.ពលករដែលទើបតែវិលត្រឡប់តាមបណ្តាច្រកទ្វារព្រំដែន ទី២. ប្រជាជនតាមមណ្ឌលចត្តាឡីស័ក ទី៣. ពលករដែលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ និងសហគមន៍គាំទ្រ ។ យើងនឹងប្រើប្រាស់រចនាសម្ព័ន្ធការងារ នៃយន្តការអន្តរស្ថាប័នដែលមានស្រាប់ពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋាន និងអង្គការដៃគូនានាក្នុងខេត្តគោលដៅ របស់អង្គការ UNFPA, IOM, WHO, UNICEF ។ល។ កម្មវិធី នឹងមានការផ្តល់ជូនដូចជា សម្ភារៈអនាម័យ ដូចជា សាប៊ូ ម៉ាស់ ទឹកលាងដៃ ជាដើម... និងការផ្តល់សេវាសុខភាព សម្រាប់ ស្ត្រី កុមារ ទារក សេវាសុខភាពផ្លូវភេទ ផ្អែកលើស្ថានភាពយេនឌ័រ ដែលមានអង្គការ IOM និង UNFPA ជាអ្នកទទួលខុសត្រូវ។ ចំណែក អង្គការសុខភាពពិភពលោក (WHO) នឹងបន្តសហការជាមួយក្រសួងសុខាភិបាលដើម្បីធ្វើការនៅតាមសហគមន៍ ពាក់ព័ន្ធនឹងការបង្ការជំងឺកូវីដ-១៩ ចំណែកអង្គការ UNICEF នឹងផ្តោតលើការងារពាក់ព័ន្ធនឹងកុមារ ។ ដោយឡែក ចំពោះការងារជួយទ្រទ្រង់សហគមន៍ គឺត្រូវកំណត់អំពីសេចក្តីត្រូវការផ្នែកសេដ្ឋកិច្ច ជាពិសេស ស្ត្រីជាមេផ្ទះ ដោយយើងនឹងជួយពួកគាត់លើការរកប្រាក់ចំណូល បង្កើនជីវភាពរស់នៅ បើមិនដូចនេះទេ គឺពួកគាត់នឹងត្រឡប់ទៅវិញ ។ តាមការកំណត់កន្លងមក IOM គ្រោងធ្វើការក្នុងស្រុកចំនួន ៣៦ ក្នុងខេត្តទាំងបី ។ សម្រាប់ការងារនេះ យើងស្នើសុំយោបល់លើជម្រើសពីរ ក្នុងការជ្រើសរើសក្រុមគោលដៅ គឺ ទី១.ធ្វើការជ្រើសរើសពលករតាមមណ្ឌលចត្តាឡីស័ក ទី២.ជ្រើសរើសនៅក្នុងសហគមន៍របស់ពួកគាត់ ។

ពាក់ព័ន្ធនឹង សំណើនេះ **លោកជំទាវ ជូ ប៊ុនអេង** បានស្នើជម្រើសទី២ ព្រោះថា មិនអាចជ្រើសរើសពលករពីមណ្ឌលចត្តាឡីស័កដែលមិនមានការត្រៀមខ្លួនបានទេ ព្រោះត្រូវធ្វើការអង្កេត ពិភាក្សា និងវាយតម្លៃការចូលរួម និងប្រព័ន្ធគាំទ្រ តាមល័ក្ខខ័ណ្ឌគ្រោងទុក ដើម្បី ឲ្យការអនុវត្តគម្រោងទទួលបានលទ្ធផល ក្នុងរយៈពេលខ្លី ។ លោកជំទាវបានផ្តល់យោបល់ថា ដោយហេតុថា យើងចង់ធ្វើឲ្យសម្រេចគោលបំណង នៃគម្រោង ដែលមានរយៈពេលខ្លី

ដើម្បីឈានទៅពង្រីកសកម្មភាពនៅពេលបន្ទាប់ទៀត ។ យើងអាចធ្វើការងារពាក់ព័ន្ធសុខភាព និងកិច្ចការពារ ទូទាំងបីខេត្ត ឬទូទាំងប្រទេសបាន ។ តែដោយឡែក ការអនុវត្តគម្រោងផ្តល់សេវាផ្សេងទៀត និងការលើកកម្ពស់ជីវភាព គប្បីជ្រើសរើសយកឃុំ ឬសហគមន៍មួយចំនួន ក្នុងស្រុក ពីរ ឬបី ដែលមានពលករទេសន្តរប្រវេសន៍ វិលត្រឡប់ច្រើន និងផ្អែកលើល័ក្ខខ័ណ្ឌដែលបានកំណត់សម្រាប់ការជ្រើសរើស និងផ្អែកលើលទ្ធភាពនៃការគាំទ្រ ការចូលរួម និងសក្តានុពលសេដ្ឋកិច្ចក្នុងខេត្ត ជាដើម ដើម្បីធ្វើឲ្យគម្រោងសម្រេចជោគជ័យ ។

**លោកស្រី** PAULINE Tamesis ប្រធានក្រុមអង្គការសហប្រជាជាតិ និង តំណាងអង្គការសហប្រជាជាតិដទៃទៀត ឯកភាពចំពោះយោបល់នេះ ។

**លោកស្រី LI AILAN ប្រធានអង្គការសុខភាពពិភពលោក** (WHO) មានប្រសាសន៍ថា បញ្ហាវិបត្តិកូវីដ-១៩ គឺជាបញ្ហាដែលកើតឡើងទូទាំងពិភពលោក ។ មានសំនួរពីមជ្ឈដ្ឋានជាច្រើនថា ហេតុអ្វីកម្ពុជាអាចឆ្លើយតបបានជោគជ័យ?។ លោកស្រី បានឆ្លើយប្រាប់ថា ទី១ គឺដោយសារកម្ពុជាមានកិច្ចសហការល្អ តាំងពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ រហូតដល់សហគមន៍ និងបានរកដំណោះស្រាយរួមគ្នាបានយ៉ាងល្អប្រសើរ ។ ទី២ គឺមានការឆ្លើយតបឆាប់រហ័ស ទាន់ពេលវេលា តាមប្រព័ន្ធផ្តល់សេវាសុខភាព និងរួមគ្នាអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលបានយ៉ាងហ្មត់ចត់ ។ ទី៣ ជាចំណុចគន្លឹះមិនអាចខ្វះបាន គឺកម្ពុជា មានការដឹកនាំល្អ ប្រជាជនមានការយល់ដឹងច្រើន ឯកភាព និងចូលរួមសហការ ពីគ្រប់វិស័យ និងគ្រប់កម្រិត ។ ការពិតទៅ យើងបានរៀបចំមណ្ឌលចត្តាឡីស័ក ដោយយកសាលារៀន និងសណ្ឋាគារមួយចំនួន ។ តែការធ្វើបែបនេះ នឹងមានភាពប្រឈម នៅពេលដែលក្រសួងអប់រំប្រកាសបើកវិស្សមកាល ឲ្យសិស្សចូលរៀនវិញ យើងនឹងត្រូវរកកន្លែងថ្មីទៀត ហើយបើធ្វើនៅសណ្ឋាគារគឺយើងត្រូវចំណាយច្រើន ។ នេះជាបញ្ហាដែលគប្បីគិតគូរទុកជាមុន ។

**លោក** Daniel Alemu **តំណាងអង្គការ** UNFPA មានប្រសាសន៍ថា សព្វថ្ងៃប្រទេសកម្ពុជាកំពុងតែមានការងារច្រើន ជាពិសេសពាក់ព័ន្ធនឹងការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ចំពោះគម្រោងដែលយើងត្រូវធ្វើនៅក្នុងខេត្តទាំងបី គឺមានរយៈពេលតែ ៦ខែ ប៉ុណ្ណោះ ដូច្នេះយើងត្រូវធ្វើឲ្យបានជាក់លាក់ និងច្បាស់លាស់ ។ ចំពោះគម្រោងនេះយើងបានសិក្សាមួយជំហាន ហើយ ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ និងជនងាយរងគ្រោះក្នុងសហគមន៍ សំដៅឲ្យមាននិរន្តរភាពក្នុងការស្ថានភាពរស់នៅ ។

**លោកស្រី** LUDA SOLEN Chief Child Protection of UNICEF មានប្រសាសន៍ថា ចំពោះអង្គការ UNICEF បានផ្តោតទៅលើការងារការពារកុមារ ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានសហការជាមួយអាជ្ញាធរខេត្តបាត់ដំបង និងបន្ទាយមានជ័យ ។ យើងបានធ្វើការសម្របសម្រួលដោយបានសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការជួយដល់ជនរងគ្រោះដែលជាកុមារ ។

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានមានប្រសាសន៍ឯកភាពចំពោះការគ្រោងទុករបស់អង្គការដៃគូទាំង៥ លើការជ្រើសរើសយកខេត្តបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង ជាខេត្តគោលដៅ និងការកំណត់យកយន្តការ អន្តរស្ថាប័នដែលមានស្រាប់ ជាដៃគូអនុវត្ត ។ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានរំលឹកបន្ថែមទៀត អំពីសកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញរបស់ពលករកម្ពុជាមួយចំនួនដែលទើបនឹងវិលមកជួបជុំគ្រួសារក្នុងពេលថ្មីៗនេះ ដោយសារតែមានមេខ្យល់

អូសទាញ ដើម្បីនាំមនុស្សឆ្លងដែន យកកម្រៃ និងគ្មានការធានាអំពីសុវត្ថិភាព ។ ពលករទាំងនោះ ត្រូវចំណាយថវិកា និងប្រថុយប្រថានគ្រោះថ្នាក់ក្នុងការឆ្លងកាត់ព្រំដែន ហើយត្រូវបានអាជ្ញាធរប្រទេសថៃ ចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ជាបន្តបន្ទាប់ ។ ដូចនេះក្នុងនាមរាជរដ្ឋាភិបាល សូមបណ្តាអង្គការដៃគូទាំងអស់បន្តរួមសហការគ្នាក្នុងការទប់ស្កាត់ពលករទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែនដោយខុសច្បាប់ តាមការអំពាវនាវរបស់រាជរដ្ឋាភិបាល ក្នុងពេលដែលពិភពលោកកំពុងប្រឈមនឹងជម្ងឺរាតត្បាតកូវីដ-១៩ មិនទាន់ធូរស្រាល និងជួយសម្របសម្រួលក្នុងការដោះស្រាយបញ្ហា ជូនប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងជនងាយរងគ្រោះ ហើយសង្ឃឹមថាគម្រោងដែលត្រៀមអនុវត្តក្នុងខេត្តទាំង៣នេះ នឹងទទួលបានជោគជ័យ ដើម្បីដកស្រង់ជាមេរៀន សម្រាប់ពង្រីកបន្តទៀត ។

អ្វីដែលជាការបារម្ភរបស់លោកជំទាវគឺ គម្រោងអាចប្រឈមនឹងឧបសគ្គ បើសិនព្រះរាជាណាចក្រថៃប្រកាសបើកព្រំដែលក្នុងពេលឆាប់ៗ តាមការគ្រោងទុក គឺនៅដំណាច់ខែមិថុនានេះ ។ បើរឿងនេះកើតឡើងមែន ពលករ នឹងជ្រួលច្របល់នាំគ្នាចាកចេញត្រឡប់ទៅវិញ ដោយពិបាកគ្រប់គ្រង ។ យើងមិនទាន់បានដឹងអំពីវិធានការបន្ទាប់ និងការសម្រេចចិត្តជានយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាទេសន្តរប្រវេសន៍នេះនៅឡើយ ថាតើត្រូវបន្តចលនា ដើម្បីពន្យារការវិលត្រឡប់ដើម្បីរៀបចំនីតិវិធីគ្រប់គ្រងដែលសមស្រប? ឬក៏ត្រូវបើកចំហរឲ្យមានការវិលត្រឡប់តាមការចង់បានរបស់ប្រជាពលរដ្ឋ ឬនិយោជកថៃ ??។

ពាក់ព័ន្ធបញ្ហានេះ លោកជំទាវ បានអំពាវនាវដល់អង្គការសហប្រជាជាតិ រៀបចំកិច្ចប្រជុំសម្រាប់ប្រទេសក្នុងមហាអនុតំបន់មេគង្គ ដែលពាក់ព័ន្ធជាប្រទេសបញ្ជូន និងប្រទេសទទួល ស្តីពីវិធានការ ឬគោលនយោបាយ ពាក់ព័ន្ធទេសន្តរប្រវេសន៍ ដែលរួមទាំងការសម្រេចចិត្តក្នុងតំណាក់កាលនៃវិបត្តិខូវីដ ១៩ ដើម្បីប្រទេសនីមួយៗ មានលទ្ធភាពក្នុងការឆ្លើយតបបានច្បាស់លាស់ ។

លោកស្រី PAULINE Tamesis ប្រធានក្រុម ក៏បានឯកភាពលើក្តីបារម្ភនេះ នឹងសន្យាថា នឹងពិភាក្សាជាមួយ ក្រុមអង្គការសហប្រជាជាតិប្រចាំតំបន់ ដើម្បីរៀបចំកិច្ចប្រជុំនេះ ។ ទន្ទឹមនឹងនោះ លោកស្រី សន្យា បញ្ជូនផែនការជាសេចក្តីព្រាង ដើម្បីទុកជូនក្រុមការងារ គ.ជ.ប.ជ និងក្រសួងមហាផ្ទៃ បានពិនិត្យ និងកែលម្អ ។

លោកស្រី ស្នើសុំរៀបចំ ជា Stering Committee ដែលមានសមាសភាពចម្រុះ រដ្ឋាភិបាល និង អង្គការសហប្រជាជាតិ ដែលមានតួនាទី គាំទ្រ តាមដាន ពង្រឹង និងជួយពង្រឹងសមត្ថភាព ដល់ក្រុមការងារអនុវត្ត និងកំណត់ការជួបប្រជុំគ្នា ដើម្បី ចែករំលែកលទ្ធផល មតិយោបល់ និងបទពិសោធន៍ កែលម្អ ដើម្បីធ្វើឲ្យសម្រេចគោលដៅ និងដើម្បីចងក្រងជាមេរៀនអនុវត្តបន្ត ។

លោកស្រីស្នើសុំឲ្យNCCT និងក្រសួងមហាផ្ទៃ ជួយសម្របសម្រួល កែសម្រួលតួនាទីរបស់យន្តការជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីងាយស្រួលអនុវត្ត និងធានានិរន្តរភាពនៃកម្មវិធីបន្តរបស់រាជរដ្ឋាភិបាល ក្នុង និងក្រោយដំណាក់កាល ខូវីដ ១៩ ។

ចំពោះការរៀបចំ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នឹងគោរពសុំយកសប្តាហ៍ទី២ នៃខែកក្កដា បន្ទាប់ពីបានឯកភាពគ្នាលើគម្រោងផែនការរួចហើយ ដើម្បីគោរពសុំការដឹកនាំពីសម្តេចឧបនាយករដ្ឋមន្ត្រី ។

ជាទីបញ្ចប់ លោកជំទាវ បានធ្វើការបូកសរុបអំពីលទ្ធផលនៃកិច្ចពិភាក្សា និងថ្លែងអំណរគុណឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងតំណាងអង្គការ ដៃគូពាក់ព័ន្ធ ដែលជាសមាជិក សមាជិកា នៃកិច្ចប្រជុំ ដែលបានចូលរួមពិភាក្សា ធ្វើឲ្យយល់គ្នាកាន់តែច្រើន ឈានដល់ការឯកភាពគ្នាលើចំណុចសំខាន់ៗមួយចំនួន ដើម្បីបន្តកិច្ចសហការ ឆ្លើយតបទៅនឹងវិបត្តិ កូវីដ ១៩ ។

កិច្ចប្រជុំពិភាក្សា បានបញ្ចប់នៅវេលាម៉ោង ដប់បី និងសែសិបនាទីរសៀល ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃពុធ ៤ កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍**

ជូ_ប៊ុនអេង